C.D.R.I
ស.ប.ស.អ

# សង្ខេបសំរាប់គោលនយោបាយ

មីនា 2006, លេខ 04

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ធ្វើការស្រាវជ្រាវ និងវិភាគ ដើម្បីរួមចំណែក
ក្នុងការកសាងយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍មានចីរភាព

# ជំរើសក្នុងការគ្រប់គ្រងព្រៃឈើនៅកម្ពុជា

ហៅ-គីមស្រេង ឃ្លោក-បុត្រា កាស្មើ-ហាសិន និង គ្រីស្ទាន-ស្តុត

តាំងពីដើមទសវត្សរ៍១៩៩០ ការគ្រប់គ្រងព្រៃឈើនៅកម្ពុជាផ្តោតលើសម្បទានព្រៃឈើធំៗ ដោយមិនសូវគិតគូរពីតំរូវការរបស់ប្រជាជនមូលដ្ឋានដែលពឹងផ្អែកលើធនធានព្រៃឈើទេ ។ ជាលទ្ធផល ធនធានធម្មជាតិដ៏សំខាន់នេះ ត្រូវខូចខាតយ៉ាងធ្ងន់ធ្ងរ និងបានរួមចំណែកតិចតួចណាស់ដល់ការអភិវឌ្ឍន៍ជនបទ ។ ដូច្នេះត្រូវមានថ្នាក់មូលដ្ឋានជួយចូលរួមគ្រប់គ្រងឱ្យច្រើនឡើង ដើម្បីបង្កើនចំណែកនៃព្រៃឈើនៅក្នុងការអភិវឌ្ឍន៍ជនបទ ។ សង្ខេបគោលនយោបាយនេះព្យាយាមបង្ហាញថាតើការគ្រប់គ្រងព្រៃឈើដោយមានចីរភាពនៅតាមតំបន់ដែលបានបញ្ចប់សម្បទាន អាចរួមចំណែកបានប៉ុណ្ណា ដល់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍នៃការកាត់បន្ថយភាពក្រីក្រដែលបានបញ្ជាក់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

## សេចក្តីផ្តើម

ក្នុងទសវត្សរ៍កន្លងទៅនេះ ការគ្រប់គ្រងព្រៃឈើរបស់រដ្ឋ ផ្តោតលើការ ផលិតឈើយកពីព្រៃមានតំលៃខ្ពស់ តាមរយៈសម្បទានព្រៃឈើខ្នាតធំ ប៉ុន្តែការអនុវត្តន៍ធ្វើមិនបានល្អទេ នាំឱ្យមានការកាប់ឈើខុសច្បាប់យ៉ាងច្រើន ការខូចខាតព្រៃឈើ និងការចែករំលែកផលប្រយោជន៍មិនស្មើភាព ។ នៅខែធ្នូ ឆ្នាំ២០០១ រដ្ឋាភិបាលបានឆ្លើយតបនឹងការរិះគន់របស់អ្នកផ្តល់ជំនួយ ដោយបានផ្អាកការកាប់យកឈើរហូតដល់ពេលក្រុមហ៊ុនសម្បទានបានរៀបចំផែនការគ្រប់គ្រងថ្មីដាក់ជូនរដ្ឋបាលព្រៃឈើ (FA) អនុម័ត ។ ការត្រួតពិនិត្យផែនការគ្រប់គ្រងបានបញ្ចប់ក្នុងពេលថ្មីៗ និងបានជូនមតិថា មានតែ ២-៣ក្រុមហ៊ុនសម្បទានប៉ុណ្ណោះដែលអាចបន្តប្រតិបត្តិការក្រោយពីបានកែតំរូវផែនការថែមទៀត ។

បច្ចុប្បន្នតំបន់ដែលបានបញ្ចប់សម្បទានធំៗ នៅទំនេរចោលដោយគ្មានការគ្រប់គ្រង ហើយការខូចខាតព្រៃឈើកំពុងបន្តកើតមាន ។ ដូច្នេះត្រូវរិះរកប្រព័ន្ធគ្រប់គ្រងបែបថ្មីៗទៀត សំរាប់ធ្វើផែនការប្រើប្រាស់ព្រៃឈើដើម្បីចូលរួមចំណែកឱ្យបានកាន់តែមានប្រសិទ្ធភាពដល់ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍ជនបទ និងការអភិរក្សជីវចំរុះ ។ បច្ចុប្បន្ន រដ្ឋបាលព្រៃឈើ (FA) បានកសាងដៃគូថ្មីៗ ចំពោះការគ្រប់គ្រងព្រៃឈើ ដើម្បីបង្កើនចំណែកនៃព្រៃឈើក្នុងការសំរេចគោលដៅសហសវត្សរ៍ ។ សង្ខេបគោលនយោបាយនេះ រៀបរាប់ត្រួសៗពីបទពិសោធន៍សំខាន់ៗ ស្តីពីប្រព័ន្ធគ្រប់គ្រងព្រៃឈើកាលពីមុននៅកម្ពុជា[1] និងពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃប្រព័ន្ធទាំងនេះ និងប្រព័ន្ធផ្សេងទៀត ក្នុងការដោះស្រាយបញ្ហាគ្រប់គ្រងព្រៃឈើ ។ ការពិភាក្សាលើកតែពីបញ្ហាមួយចំនួនតូច ទាក់ទិននឹងការគ្រប់គ្រងព្រៃឈើមានចីរភាព ដើម្បីបំផុសគំនិតថាតើរាជរដ្ឋាភិបាលអាចធ្វើអ្វី ដើម្បីកាត់បន្ថយការខូចខាតព្រៃឈើនៅតាមតំបន់ព្រៃ ក្រោយពីបញ្ចប់សម្បទាន និងបង្កើនចំណែកធនធានព្រៃឈើក្នុងការអភិវឌ្ឍន៍ជនបទ ។

## បទពិសោធន៍នៃការគ្រប់គ្រងព្រៃឈើនៅកម្ពុជា

កន្លងមក បទពិសោធន៍នៅកំរិតជាតិក្នុងការគ្រប់គ្រងព្រៃឈើ ផ្តោតលើផលិតកម្មឈើ ដោយផ្តល់សម្បទានព្រៃឈើខ្នាតធំដល់សហគ្រាសពាណិជ្ជកម្ម ។ ប្រព័ន្ធនេះអនុវត្តនៅទូទាំងប្រទេសលើព្រៃឈើមានតំលៃខ្ពស់ប្រមាណ ៧លានហ.ត រឺជិត ៤0% នៃផ្ទៃដីសរុបនៅកម្ពុជា ។ ប្រព័ន្ធមួយទៀតដែលថ្នាក់ជាតិបានយកចិត្តទុកដាក់ច្រើននាពេលថ្មីៗ គឺសហគមន៍ព្រៃឈើ (CF) ដែលឈរលើប្រពៃណីប្រើប្រាស់ព្រៃដ៏យូរលង់ ដោយសហគមន៍រស់នៅក្នុង រឺ នៅក្បែរតំបន់ព្រៃឈើ ។ សហគមន៍ទាំងនេះពឹងផ្អែកយ៉ាងខ្លាំងលើធនធានព្រៃឈើក្នុងការចិញ្ចឹមជីវិត ហើយជាយូរឆ្នាំក្រោយមក ក៏បង្កើតបានប្រព័ន្ធគ្រប់គ្រងព្រៃសហគមន៍ដោយខ្លួនឯង[1] ។ ថ្នាក់ជាតិក៏បានទទួលស្គាល់ប្រព័ន្ធនេះបន្តិចម្តងៗ ហើយនៅឆ្នាំ២០០២ FA បានរកឃើញព្រៃសហគមន៍ប្រហែល ៦៤.000ហ.ត ដែលមានទំរង់ផ្សេងៗគ្នា ទៅតាមស្ថានភាពនៅមូលដ្ឋាន ។ រដ្ឋាភិបាលមិនបានទទួលស្គាល់វាទាំងអស់ទេ ហើយគេគិតថា ការគ្រប់គ្រងព្រៃសហគមន៍ជាក់ស្តែងមានទំហំធំជាងនេះ ។

## ព្រៃសម្បទានខ្នាតធំនៅក្នុងព្រៃផលិតកម្ម

ប្រព័ន្ធព្រៃសម្បទាននៅកម្ពុជា ផ្អែកលើកិច្ចព្រមព្រៀងវិនិយោគរយៈ ២៥ឆ្នាំ រវាងរដ្ឋាភិបាល និងក្រុមហ៊ុនសម្បទានឯកជនដែលភាគច្រើនមានម្ចាស់ជាជនបរទេស ។

នៅក្នុងកិច្ចព្រមព្រៀង ម្ចាស់សម្បទានសន្យាបង្កើតឧស្សាហកម្មកែច្នៃ បង់សួយសារ និងអនុវត្តប្រព័ន្ធគ្រប់គ្រងដោយចីរភាព ដើម្បីបានសិទ្ធិប្រមូលផលនៅតាមតំបន់សម្បទាន ។ វាជាកិច្ចសហការរវាងរដ្ឋ-ឯកជន ហើយ FA ដែលជាតំណាងរដ្ឋ ត្រូវកសាងសេចក្តីណែនាំអំពីការគ្រប់គ្រង និងពង្រឹងការអនុវត្តន៍ តាមរយៈការអនុម័ត និងតាមដាន ផែនការគ្រប់គ្រងព្រៃឈើជាយុទ្ធសាស្ត្រ (SFMPs) រៀបចំឡើងដោយម្ចាស់សម្បទាន ។ គោលគំនិតនៃប្រព័ន្ធនេះ គឺរដ្ឋាភិបាលនឹងបានចំណូលហិរញ្ញវត្ថុយ៉ាងងាយបំផុតពីការបង់សួយសារលើសម្បទាន ។

ការអនុវត្តន៍ព្រៃសម្បទានអន់ខ្សោយណាស់ ហើយមានការរិះគន់ពីការកាប់ឈើគ្មានការត្រួតពិនិត្យយ៉ាងច្រើន ដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានព្រៃឈើ ទំនាស់សិទ្ធិគ្នាជាមួយសហគមន៍មូលដ្ឋាន និងការរួមចំណែកដ៏តិចតួចដល់ការកាត់បន្ថយភាពក្រីក្រនៅជនបទ[២] ។ ការសើរើពិនិត្យឡើងវិញមួយខ្សែ[៣] នាំឱ្យមានការបញ្ចប់សម្បទានទាំងអស់ និងការផ្អាកការប្រមូលផលឈើហ៊ុបនៅខែធ្នូ ២០០១ រហូតដល់ក្រុមហ៊ុនបានពិនិត្យ SFMPs ឡើងវិញ និងទទួលការអនុមតិជាថ្មីពី FA ។ ការសើរើពិនិត្យ និងវាយតំលៃកំពុងបន្តរហូតដល់បច្ចុប្បន្ន ហើយអ្នកត្រួតពិនិត្យឯករាជ្យ[៤-៥] បានសន្និដ្ឋានថា សម្បទានិកមានការគិតគូររយៈពេលខ្លីក្នុងការគ្រប់គ្រងព្រៃឈើដោយផ្តោតទាំងស្រុងលើការរកស៊ីក្នុងរយៈពេលខ្លី ជាជាងចីរភាពរយៈពេលវែង ក្នុងនេះមានទាំងទិដ្ឋភាពខាងបរិស្ថាននិងសង្គមកិច្ចផង ។ដូច្នេះមានតំរូវការយ៉ាងខ្លាំងនូវប្រព័ន្ធដែលមានការទទួលខុសត្រូវច្រើនខាងសង្គមកិច្ច ដើម្បីដោះស្រាយបញ្ហាដែលបានជួបប្រទះនៅក្នុងប្រព័ន្ធសម្បទាន ។ នៅឆ្នាំ២០០៤ ការសើរើពិនិត្យពីឯករាជភាពនៃវិស័យព្រៃឈើ (IFSR) បានផ្តល់មតិថា ប្រព័ន្ធសម្បទានគួរតែបោះបង់ចោល ពីព្រោះ ក្រុមហ៊ុនមិនទំនងជាចូលរួមក្នុងការគ្រប់គ្រង សំរាប់រយៈពេលវែងទេ ដោយសារតែការខាតបង់ក្នុងអំឡុងពេលផ្អាក ។ ម្យ៉ាងទៀត មានការប្រឹងប្រែងច្រើនណាស់លើការកែលំអប្រព័ន្ធ និងសើរើពិនិត្យ SFMPs ។ ការពិនិត្យឡើងវិញចុងក្រោយ ឆ្នាំ២០០៥ បានផ្តល់មតិថា សម្បទានព្រៃឈើ ២-៣កន្លែង អាចធ្វើបន្តបាន បើសិនអាចដោះស្រាយបាននូវបញ្ហាទាក់ទិននឹងការបែងចែកតំបន់ព្រៃ ការប៉ាន់ស្មានលើសពីចំនួនឈើកាប់ប្រចាំឆ្នាំ កិច្ចការពារដើមដ៏រទឹកមិនគ្រប់គ្រាន់ និងកង្វះការចូលរួមពីសហគមន៍ ។ ផ្អែកលើមតិនេះ ធនាគារពិភពលោកបានផ្តល់យោបល់ថា សម្បទានទាំងអស់គួរបញ្ឈប់ ហើយឥឡូវនេះ FA ត្រូវសំរេចថាតើគួរធ្វើយ៉ាងណាចំពោះសម្បទានព្រៃឈើនៅសេសសល់ចុងក្រោយ ។គួរកត់សំគាល់ថា ទោះជាសម្បទានព្រៃឈើត្រូវបញ្ឈប់ រឺបន្ត ការពន្យាពេលសំរេចចិត្តថា ត្រូវបញ្ឈប់ រឺបន្តសម្បទាន វាមិនអាចការពារតំបន់បញ្ចប់សម្បទាន ឱ្យបានរួចផុតពីការខូចខាតឡើយ ។ ក្នុងស្ថានភាពបានធ្វើផ្លូវហើយ និងគ្មានការលើកទឹកចិត្តឱ្យការពារធនធានព្រៃឈើ, តំបន់ទាំងនេះ បានក្លាយទៅជា "តំបន់បើកចំហ" ដែលអាចខូចខាតថែមទៀត ដោយសារម្ចាស់រោងអារឈើ និងឡដុតធ្យូង ។ រឿងនេះឃើញកើតមានច្រើនហើយក្នុងទូទាំងប្រទេស ហើយនឹងបន្ត រហូតដល់ពេលមានការដាក់អនុវត្តប្រព័ន្ធគ្រប់គ្រងថ្មី[៦] ។

នាពេលនេះ សកម្មភាពក្រោយពេលបញ្ចប់សម្បទាន បានកាត់បន្ថយលទ្ធភាពផលិតនៃព្រៃឈើសេសសល់សន្សឹមៗ ដោយសារការកាប់ឈើមានអង្កត់ផ្ចិត មធ្យម (៤០-៦០ស.ម) ដែលអាចដុះលូតលាស់ធំជាងកំរិតអប្បបរមាអាចកាប់ ៦០ស.ម ក្នុងរយៈពេល ២៥ឆ្នាំទៀត ។ ដូច្នេះ ផលវិបាកនៃសម្បទានព្រៃឈើនៅតែមិនទាន់ដោះស្រាយ រឺឯរដ្ឋាភិបាលក៏ដល់ពេលវេលាត្រូវធ្វើសកម្មភាព បើសិនជាចង់បញ្ឈប់និន្នាការបំផ្លាញធនធានព្រៃឈើ ។ គន្លឹះសំខាន់ដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវផ្តល់ការលើកទឹកចិត្តដល់អ្នកគ្រប់គ្រងជាក់ស្តែង អោយការពារធនធានព្រៃឈើ ដោយផ្តល់សិទ្ធិអំណាចឱ្យប្រជាជនមូលដ្ឋានជួយគ្រប់គ្រង ។

## សហគមន៍ព្រៃឈើ

សហគមន៍ព្រៃឈើ គឺជាការផ្តល់សិទ្ធិអំណាចឱ្យសហគមន៍មូលដ្ឋានគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើឱ្យមានចីរភាព និងជួយការពារធនធានព្រៃឈើ ។ គោលគំនិតគឺ បើសិនប្រជាជនមូលដ្ឋានមានសិទ្ធិច្បាស់លាស់ក្នុងការប្រមូលផល រឺប្រើប្រាស់ព្រៃឈើ ពួកគេមានការលើកទឹកចិត្តឱ្យការពារព្រៃឈើ ។ ដូច្នេះមូលដ្ឋានគ្រឹះនៃ CF គឺសហគមន៍ប្រើប្រាស់ព្រៃឈើ អាចដកអ្នកដទៃចេញពីតំបន់ខ្លួន ដើម្បីធ្វើការប្រមូលផលដោយមានចីរភាព ។ចំពោះថ្នាក់ជាតិ វាជាវិធីមួយដែលចំណាយតិចដើម្បីការពារព្រៃ ហើយវាមានប្រយោជន៍នៅពេលរដ្ឋខ្វះខាតធនធាន ដើម្បីពង្រឹងកិច្ចការពារព្រៃ ។ វាក៏ផ្តល់ឱកាសល្អៗសំរាប់ការអភិវឌ្ឍន៍ជនបទ ពីព្រោះផលប្រយោជន៍បានពីព្រៃឈើអាចផ្ទេរដោយផ្ទាល់ទៅឱ្យសហគមន៍មូលដ្ឋាន ។

នៅកម្ពុជា បទពិសោធន៍ CF បានវិវត្តឡើង នៅពេលសហគមន៍ស្ថិតក្នុងតំបន់សម្បទានព្រៃឈើធំៗ មើលឃើញពីការថយចុះលទ្ធភាពប្រើប្រាស់ព្រៃឈើ ។ ដំណើរការនេះមួយភាគធំបំផុតដោយ NGOs ដូច្នេះគំរូគ្រប់គ្រងប្រែប្រួលខុសគ្នាទៅតាមគោលដៅរបស់ NGOsពាក់ព័ន្ធ ។ ថ្នាក់ជាតិបានទទួលស្គាល់ CF ដោយយឺតៗ ដោយបានចេញអនុក្រឹត្យស្តីពី CF នៅឆ្នាំ២០០៣ ។ថ្វីបើមានការទិតៀនអនុក្រឹត្យថា ផ្តោតខ្លាំងពេកទៅលើការត្រួតពិនិត្យរបស់រដ្ឋាភិបាល ប៉ុន្តែវាជាជំហានទីមួយដ៏សំខាន់សំរាប់ការទទួលស្គាល់ CF តាមច្បាប់នៅកម្ពុជា ។ តាមការមើលឃើញនៅមូលដ្ឋាន ការប្រឹងប្រែងបង្កើត CF បានផ្តោតលើតែតំបន់ព្រៃខូចខាត ។ ក្នុងស្ថានភាពនេះ សហគមន៍នានាមិនសូវជឿជាក់ទេថា ខ្លួនអាចទាញផលប្រយោជន៍អ្វីបានពីតំបន់CF ។ បើសិនចង់ឱ្យ CF អាចទ្រទ្រង់ខ្លួនឯងបាន មូលដ្ឋានធនធានត្រូវមានគុណភាពល្អ និងផលប្រយោជន៍នាពេលអនាគត ក៏ត្រូវធានាច្បាស់លាស់ ដើម្បីរ៉ាប់រងចំណាយប្រតិបត្តិការនៅមូលដ្ឋាន ។ យោងតាមស្ថានភាពសព្វថ្ងៃនៃកម្មសិទ្ធិដីធ្លីមិនរឹងប៉ឹង និងធនធានព្រៃខូចខាត បែងចែកទៅឱ្យ CF ផលប្រយោជន៍ទៅអនាគតដែលជាគ្រឿងលើកទឹកចិត្តក្នុងរឿងនេះ ហាក់ដូចជា មិនគ្រប់គ្រាន់ទេសំរាប់កសាងប្រព័ន្ធអាចរស់បានដោយខ្លួនឯង ។ បញ្ហាចំបងៗ រួមមាន សិទ្ធិមិនច្បាស់លាស់លើការលក់ផលិតផលប្រមូលបាន ចំណាយលើការប្រមូលផលខ្ពស់ ការបង់កំរៃខ្ពស់នៅតាមកន្លែងផ្សេងៗក្នុងការលក់ចេញទៅទីផ្សារ និងកង្វះយន្តការច្បាស់លាស់សំរាប់បែងចែកចំណូលនៅក្នុងសហគមន៍ ។ CF ពិតជាមានលទ្ធភាពជួយរដ្ឋាភិបាលក្នុងការសំរេចគោលដៅសហសវត្សរ៍ ប៉ុន្តែការប្រឈមនានា ត្រូវតែដោះស្រាយនៅកំរិតមូលដ្ឋាន និងកំរិតជាតិ ដើម្បីបង្កើនការលើកទឹកចិត្តនៅមូលដ្ឋាន ។

## ការដាក់ដេញថ្លៃព្រៃគុបប្រចាំឆ្នាំៈ វិធីថ្មីកាន់តែមជ្ឈការ

ដោយសារប្រព័ន្ធសម្បទានទទួលបរាជ័យ FA បានរៀបចំវិធីថ្មីមួយដើម្បីគ្រប់គ្រងការប្រមូលផលឈើតាមរយៈការ "ដាក់ដេញថ្លៃព្រៃគុបប្រចាំឆ្នាំ" ដោយយោងតាមការរៀបចំឡើងវិញក្នុងពេលថ្មីៗនៃការគ្រប់គ្រងព្រៃនៅថ្នាក់ជាតិ និងច្បាប់ព្រៃឈើឆ្នាំ២០០២ ដែលផ្តល់ឱ្យ FA នូវការទទួលខុសត្រូវ និងសិទ្ធិគ្រប់គ្រងច្បាស់លាស់លើធនធានព្រៃឈើ ។ ក្នុងវិធីថ្មីនេះ សិទ្ធិប្រមូលផលប្រចាំឆ្នាំត្រូវបែងចែកតាមរយៈ

ការដាក់ដេញថ្លៃព្រៃគុបជាសាធារណៈ ដែលផ្អែកលើផែនការគ្រប់គ្រងព្រៃរៀបចំដោយនាយផ្នែកនៃ FA ។ ប៉ុន្តែវិធីនេះចោទបញ្ហាធំៗមួយចំនួន ។ ទី១ FA តាំងខ្លួនឯងជាអ្នកធ្វើផែនការផង និងអ្នកអនុម័ត ដោយគ្មានការពិនិត្យមើល និងថ្លឹងអំណាច ។ រឿងនេះបង្កឱ្យមានការយកកំរៃផ្សេងៗ ពីព្រោះគ្មានយន្តការទាមទារគណនេយ្យភាព (ការទទួលខុសត្រូវ) ។ ម្យ៉ាងទៀត វាហាក់ផ្តោតលើផលិតកម្មឈើជាលក្ខណៈពាណិជ្ជកម្ម ដោយមានការចូលរួមតិចតួចបំផុតពីសហគមន៍មូលដ្ឋាន ។ ដូច្នេះប្រព័ន្ធនេះមិនច្បាស់ថា អាចដោះស្រាយបញ្ហាចោទខាងសិទ្ធិ និងអ្នកម៉ៅការបន្តបានទេ ។ អ្នកផ្តល់ជំនួយបានលើកពីការបារម្ភចំពោះវិធីថ្មីនេះ[6] ហើយការសើរើពិនិត្យ SFMPs នៅឆ្នាំ២០០៥ បានបង្ហាញភស្តុតាងច្បាស់ ដូចបទពិសោធន៍នៅប្រទេសដទៃទៀតដែរថា ប្រព័ន្ធដាក់ដេញថ្លៃព្រៃគុបប្រចាំឆ្នាំ អាចមិនស៊ីគ្នាជាមួយនឹងការគ្រប់គ្រងព្រៃឈើអោយមានចីរភាពទេ ។

## ការគ្រប់គ្រងព្រៃឈើជាដៃគូ ~ វិធីជំនួសការគ្រប់គ្រងព្រៃឈើបែបមជ្ឈការ

មានសំណើឡើងថា FA គួរគិតគូរប្រើវិធីគ្រប់គ្រងព្រៃឈើឱ្យបានទូទៅឡើងដោយផ្សារភ្ជាប់ទៅនឹងវិមជ្ឈការកំពុងបន្តទៅមុខ ។ វិធីនេះអាចផ្អែកលើភាពជាដៃគូរវាងរដ្ឋ និងឃុំ ដោយឃុំជាអ្នកធ្វើផែនការព្រៃឈើឃុំ (CFP) ហើយ FA ជាអ្នកអនុម័ត ។ សួយសារ/កំរៃមួយភាគ ត្រូវបែងចែកឱ្យឃុំសំរាប់ដាក់ចូលមូលនិធិអភិវឌ្ឍន៍ ។ បច្ចុប្បន្ន មិនទាន់មានច្បាប់ច្បាស់លាស់សំរាប់ការគ្រប់គ្រងព្រៃឈើជាដៃគូទេ ដូច្នេះ FA អាចគិតគូរផ្តល់សិទ្ធិឱ្យឃុំ ក្នុងលក្ខខណ្ឌជាក់លាក់ ជំនួសឱ្យប្រព័ន្ធសម្បទាន និងការដាក់ដេញថ្លៃព្រៃគុបប្រចាំឆ្នាំ ។

គោលគំនិតនៃប្រព័ន្ធគ្រប់គ្រងព្រៃឈើជាដៃគូគឺ ឃុំ (និងអ្នកគ្រប់គ្រងជាក់ស្តែងក្នុងឃុំ) នឹងមានការលើកទឹកចិត្តឱ្យ ការពារធនធានព្រៃឈើក្នុងតំបន់របស់ខ្លួនទប់ទល់នឹងការប្រមូលផលខុសច្បាប់ និងទាមទារឱ្យរដ្ឋទប់ស្កាត់ក្រុមអ្នកកាប់ឈើខុសច្បាប់កាន់តែខ្លាំង ។ គួរសំគាល់ថា វិធីជាដៃគូនេះមិនមែនសំរាប់ជំនួស CF ទេ ។ នៅក្នុង CFP មានវិធីអនុវត្តច្រើនបែប ក្នុងនេះមានទាំង CF និងការម៉ៅការឱ្យឯកជនធ្វើផង ។ ប៉ុន្តែប្រព័ន្ធនេះក៏មានបញ្ហាខ្លះដែរ ដូច្នេះការអនុវត្តន៏ត្រូវតែតាមដានជាប់រហូត ។ ការបារម្ភមួយគឺ វិមជ្ឈការជាគោលគំនិតថ្មីនៅកម្ពុជា ហើយការគ្រប់គ្រងចំណូលច្រើនពីព្រៃឈើអាចធ្វើឱ្យក្រុមប្រឹក្សាឃុំបាត់លំនឹង ។ សមត្ថភាពគ្រប់គ្រងព្រៃឈើរបស់ក្រុមប្រឹក្សាឃុំក៏មានកំរិតដែរ ដូច្នេះអាចពឹងផ្អែករហូតលើជំនួយបច្ចេកទេសពី FA ដែលមិនទាំងច្បាស់ថាតើត្រូវផ្តល់របៀបណាផង ។ បើសិនមានផលប្រយោជន៍ហូរចូលច្រើនពេក សហគមន៍មូលដ្ឋានអាចជួបគ្រោះថ្នាក់ រដ្ឋដកយកសិទ្ធិវិញ ដូចធ្លាប់កើតមានហើយនៅប្រទេសឯទៀត ។

## ការដាំព្រៃឈើ រឺសហគ្រាសឯកជនខ្នាតតូច

មកដល់សព្វថ្ងៃ ព្រៃដាំឡើងវិញមានតែ 0,១% នៃគំរបព្រៃឈើនៅកម្ពុជាប៉ុណ្ណោះ[4] និងភាគច្រើនជាប្រភេទដើមឈើនាំចូលដែលដុះលឿន សំរាប់ធ្វើក្រដាសនៅលើសម្បទានដីធំៗ ធ្វើឱ្យអ្នកសង្កេតការណ៍មួយចំនួនមិនទុកចិត្តសោះថាវាជួយរួមចំនែកដល់ការអភិវឌ្ឍន៍ជនបទ ។ បញ្ហាធំៗគឺការដាំព្រៃឈើធ្វើឡើងលើដីដែលសហគមន៍ទាមទារ និង/រឺ គ្រាន់តែជាលេសសំរាប់យកធនធានឈើនៅលើដីនោះ ។

ប៉ុន្តែចំការដាំឈើឧស្សាហកម្មខ្នាតធំ គ្រាន់តែជាវិធីមួយសំរាប់ដាំព្រៃឡើងវិញប៉ុណ្ណោះ ពីព្រោះមានប្រព័ន្ធដាំឈើនៅមូលដ្ឋានច្រើនទៀត ។ ពិនិត្យតាមនិន្នាការខូចខាតព្រៃធម្មជាតិសព្វថ្ងៃនេះ ត្រូវស្វែងរកឱ្យបាននូវរបស់សំរាប់ជំនួសឈើ និងអុសដែលកាប់យកពីព្រៃធម្មជាតិ ។ ឧទាហរណ៍ ចំការដាំឈើពូជក្នុងស្រុកមានតំលៃខ្ពស់ អាចជួយផ្គត់ផ្គង់ឈើហ៊ុបបានច្រើនទៅអនាគត ។ ចំការខ្នាតតូចគ្រប់គ្រងដោយកសិករមូលដ្ឋាននិង/រឺ ចំការដៃគូរវាងសហគមន៍មូលដ្ឋាននិងវិនិយោគិនឯកជនអាចអនុវត្តសាកល្បងក្រោមការត្រួតពិនិត្យយ៉ាងជិតដល់ ។ វិធីមួយទៀតសំរាប់លើកកំពស់ជីវភាពប្រជាជននៅជនបទ គឺការបង្កើតចំការឈើខ្នាតតូចក្នុងព្រៃសហគមន៍ រឺការជួយសំរួលដល់ការបង្កើតសហគ្រាសអនុផលព្រៃឈើឯកជនខ្នាតតូច ។ បញ្ហាប្រឈមសំរាប់ចំការខ្នាតតូច គឺការកំណត់ថា អនុផលព្រៃឈើណាមានតំរូវការពីទីផ្សារ និងការផ្សារភ្ជាប់ព័តិមាននេះទៅនឹងការយល់ដឹងនៅមូលដ្ឋានអំពីអេកូឡូស៊ីអនុផលព្រៃឈើប្រភេទនោះតាមរយៈសកម្មភាពមានការចូលរួម ។ ម្យ៉ាងទៀត គួរដោះស្រាយទាំងនៅកំរិតមូលដ្ឋាន និងកំរិតជាតិនូវបញ្ហាទាក់ទិននឹងរបៀបរបបប្រមូលកំរៃក្រៅផ្លូវការលើទីផ្សារអនុផលព្រៃឈើ ។

## កំណត់សំគាល់


1. ITTO (2005): Cambodia's challenges. ITTO Tropical Forest Update 15/1 2005
2. McKenney, B., Chea, Y., Tola, P. and Evans, T. (2004): Focusing on Cambodia's High Value Forests: Livelihoods and Management. Special Report by CDRI and Wildlife Conservation Society (WCS), Phnom Penh.
3. e.g. ADB (2000): Cambodia Forest Concession Review Report. TA – 3152 – CAM, Sustainable Forest Management Report, Asian Development Bank (ADB).
4. IFSR (2004): Independent Forest Sector Review. The Forest Sector in Cambodia. Part I. Policy choices, issues and options.
5. GFA (2005): Cambodia – Review of Strategic Forest Management Plans prepared by Concession Companies operating in Cambodia - Part II – Final Report. GFA Consulting Group, Hamburg, Germany.
6. World Bank (2005): Letter dated Nov. 24, 2005 available on the homepage of the Technical Working Group on Forestry and Environment at http://www.twgfe.org/Papers.php
7. Prom, T. and B. McKenney (2003): Trading Forest Products in Cambodia: Challenges, Threats, and Opportunities for Resin. CDRI Working Paper No. 28, Phnom Penh.

## សេចក្ដីសន្និដ្ឋាន

*ការកាន់កាប់ និងការចុះបញ្ជីដីធ្លី*

កម្មសិទ្ធិដី និងសិទ្ធិប្រើប្រាស់ដីច្បាស់លាស់ និងមានការធានា គឺចាំបាច់ណាស់ សំរាប់ឲ្យវិនិយោគិនបរទេស និងសហគមន៍មូលដ្ឋាន ធ្វើវិនិយោគរយៈពេលវែងនៅក្នុងការគ្រប់គ្រងព្រៃឈើមានចីរភាព ។ ដូច្នេះ គួរប្រើវិធីបង្កើនបង្កើយដំណើរការចុះបញ្ជីដីធ្លីរួមគ្នាសិន មុនពេលធ្វើការទាមទារដីថ្មីទៀត ។ នៅពេលសិទ្ធិរបស់ប្រជាជនមូលដ្ឋានមានការធានាតាមរយៈការចុះបញ្ជីដីធ្លី ព្រំប្រទល់ដីព្រៃអចិន្ត្រៃយ៍អាចកំនត់បាននៅលើផែនទី និងនៅលើដី ។ រឿងនេះគួរមានអាទិភាពខ្ពស់ ដើម្បីជៀសវាងទំនាស់ពីសិទ្ធិក្នុងការគ្រប់គ្រងព្រៃឈើទៅអនាគត ។

*ការគ្រប់គ្រងព្រៃឈើផលិតកម្ម*

នាបច្ចុប្បន្ន ដីព្រៃធំៗជាច្រើនត្រូវទុកចោលដោយគ្មានការគ្រប់គ្រង ហើយអាចទទួលការខូចខាតថែមទៀត ។ ព្រៃសម្បទានមានអនាគតមិនច្បាស់លាស់ទេ ហើយប្រព័ន្ធដាក់ព្រៃគុបដេញថ្លៃប្រចាំឆ្នាំ ហាក់ដូចមិនសូវមានប្រសិទ្ធភាពទេ ក្នុងការដោះស្រាយបញ្ហាពីមុនៗទាក់ទិននឹងការចូលរួមពីសហគមន៍ និងទំនាស់លើសិទ្ធិ ។ ដូច្នេះគួរស្រាវជ្រាវពីវិធីគ្រប់គ្រងថ្មីៗដែលបែងចែកការទទួលខុសត្រូវទៅឲ្យអាជីវករកាប់ឈើ និងប្រជាជនមូលដ្ឋាន ហើយ FA គួរធ្វើការតែជាអាជ្ញាធរខាងច្បាប់ជួយជំរុញការគ្រប់គ្រងឲ្យមានចីរភាពតាមរយៈការដាក់អនុវត្តន៍ច្បាប់ប្រឆាំងនឹងសកម្មភាពកាប់ឈើខុសច្បាប់ និងគ្មានចីរភាព ។

*ការគ្រប់គ្រងព្រៃជាដៃគូ*

នៅកម្ពុជា មានឱកាសល្អច្រើនសំរាប់ការគ្រប់គ្រងព្រៃឲ្យមានចីរភាព ដោយការធ្វើជាដៃគូរវាងរដ្ឋ និងសហគមន៍ នៅក្នុងដំណើរការវិមជ្ឈការដែលកំពុងបន្តទៅមុខ ។ វិធីនេះទន់ភ្លន់ងាយបត់បែន ក្នុងការដោះស្រាយល័ក្ខខ័ណ្ឌផ្សេងៗខាងសេដ្ឋកិច្ច-សង្គមកិច្ច និងបរិស្ថាន ។ ប៉ុន្តែគេមិនទាន់បានសាកល្បងវិធីនេះនៅឡើយទេ ហើយការបែងចែកចំណូលច្រើនៗទៅឲ្យសហគមន៍មូលដ្ឋាន ក៏មិនមែនអត់បញ្ហាដែរ ។ វិធីនេះក៏មិនទាន់មានបទប្បញ្ញត្តិច្បាប់ណែនាំដែរ ។ ប៉ុន្តែ FA អាចគិតគូរផ្ដល់សិទ្ធិគ្រប់គ្រងទៅឲ្យសហគមន៍ ដោយមានការពិនិត្យតាមដានយ៉ាងជិតដល់ ដើម្បីស្វែងរកប្រព័ន្ធដ៏សមស្របមួយ ។

*សហគមន៍ព្រៃឈើ (CF)*

អនុក្រឹត្យថ្មីឆ្នាំ២០០៣ មានចែងពីសហគមន៍ព្រៃឈើ ប៉ុន្តែវាផ្ដោតខ្លាំងពេកលើការគ្រប់គ្រងពីរដ្ឋាភិបាលកណ្ដាល ។ ទោះយ៉ាងនេះក្ដី វាបើកចំហឲ្យមានការចូលរួមពីអ្នកគ្រប់គ្រងព្រៃជាក់ស្ដែងក្នុងកិច្ចការពារព្រៃឈើ ។ មកទល់សព្វថ្ងៃ CF ផ្ដោតតែលើព្រៃខូតខាតដោយមានការលើកទឹកចិត្តតិចតួចប៉ុណ្ណោះ សំរាប់ជួយឲ្យប្រព័ន្ធ CF អាចផ្គត់ផ្គង់ហិរញ្ញវត្ថុ និងរស់ដោយខ្លួនឯងបាន ។ ប៉ុន្តែក្នុងនេះត្រូវបើកឱកាសឲ្យមានការរីកលូតលាស់ឲ្យលើសពីការស្ដារព្រៃខូចខាត ឲ្យទៅជាការគ្រប់គ្រងព្រៃមានតំលៃខ្ពស់ផង ។ វាជាការសំខាន់ណាស់ដែល ត្រូវផ្ដល់ការលើកទឹកចិត្តច្រើនទៀតក្នុងទំរង់ជាផលប្រយោជន៍នាពេលអនាគតសំរាប់សហគមន៍ បើសិនចង់អោយ CF រីកលូតលាស់មានចីរភាពឡើង ។

*ចំការ/សហគ្រាសឯកជនខ្នាតតូច*

ការដាំព្រៃឈើត្រូវតែធំទូលាយជាងផលិតកម្មខ្នាតធំដែលដាំឈើដុះលឿនសំរាប់ធ្វើក្រដាសនោះទៅទៀត ។ ក្នុងនេះគួរស្រាវជ្រាវថែមទៀត ពីលទ្ធភាពធ្វើចំការឯកជនខ្នាតតូច ផលិតឈើហ៊ុបពាណិជ្ជកម្ម រឺអនុផលព្រៃឈើនានា ដើម្បីធានាក្នុងការរួមចំណែកអភិវឌ្ឍន៍ធនធានព្រៃឈើនៅតាមជនបទ ។

**ខបសអ សូមថ្លែងអំណរគុណដល់ការឧបត្ថម្ភរបស់ ដានីដា សំរាប់កម្មវិធី "គ្រប់គ្រងធនធានធម្មជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រៈ ការស្រាវជ្រាវគោលនយោបាយស្ដីពីជំរើសការគ្រប់គ្រង និងផលចំណេញដែលបានពីធនធាន" ។**

©រក្សាសិទ្ធិឆ្នាំ២០០៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ផ្ទះលេខ 56 ផ្លូវលេខ 315 ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា ( ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា)

ទូរស័ព្ទ: (855-23) 881-384/881-701/ 881-916/ 883-603 ទូរស័ព្ទ/ទូរសារ: (855-23) 880-734

អ៊ីមែល: cdri@camnet.com.kh http://www.cdri.org.kh